២



# សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

## និយមន័យ

បុគ្គលគ្រប់រូបដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង (ឬសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង)។ សិទ្ធិនេះអនុវត្តមុនដំណាក់កាលជំនុំជម្រះ និងនៅពេលជំនុំជម្រះ និងមានទិដ្ឋភាពពីរៈ

ជនជាប់ចោទមិនអាចត្រូវបានបង្ខិតបង្ខំ ឬបង្ខំឱ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។ ក្នុងការអនុវត្តនេះ មានន័យ ថានៅពេលដែលជនជាប់ចោទ ធ្វើការសារភាពគឺត្រូវធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ មិនថាដោយផ្ទាល់ ឬដោយប្រយោល តាមផ្លូវកាយ ឬផ្លូវចិត្ត។

ជនជាប់ចោទមិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯងតាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងឡើយ។ សិទ្ធិប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯងគឺជាធាតុផ្សំយ៉ាងសំខាន់នៃដំណើរការនីតិវិធីតុលាការ ដោយសារតែជាការលំបាកក្នុងការគិតដល់ការជំនុំជម្រះដោយយុត្តិធម៌ នៅពេលដែលជនជាប់ចោទត្រូវបានបង្ខំឱ្យផ្តល់ភស្តុតាងដាក់បន្ទុកលើខ្លួនឯង។

ហេតុដូច្នេះ សិទ្ធិនេះត្រូវបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការទទួលស្គាល់ជាអន្តរជាតិលើការហាមឃាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ ការសារភាព ឬចម្លើយណាមួយត្រូវបានទទួលតាមរយៈការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬទម្រង់ផ្សេងៗទៀតនៃការធ្វើបាប នោះត្រូវបានដកចេញពីភស្តុតាងដែលបង្ហាញនៅពេលសវនាការ។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ



សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានចែងយ៉ាងច្បាស់ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ (ឆ) មិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពថាមានពិរុទ្ធ”។ សិទ្ធិនេះក៏មានចែងនៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀតដែរ រួមមាន មាត្រា៤០(២)(iv) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង មាត្រា ១ និងមាត្រា ៤ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

### ច្បាប់ជាតិ

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងត្រូវបានចែងការពារជាក់លាក់នៅក្នុងមាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា “ច្បាប់រាំងរងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ”។ សិទ្ធិនេះក៏ត្រូវបានធានានៅក្នុងប្រទេសកម្ពុជាផងដែរតាមរយៈបញ្ញត្តិទូទៅ និងជាក់លាក់ ដែលមានចែងនៅក្នុងលិខិតូបករណ៍មួយចំនួន រួមមាន មាត្រា ១៤៥ និង៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និង៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។



# សារសំខាន់



សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺជាធាតុផ្សំជាមូលដ្ឋាននៃគោលការណ៍សន្មតទុកជាមុនថាគ្មានទោសដែលបន្ទុកនៃភស្តុតាងទៅលើអយ្យការ។ ការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិមូលដ្ឋានសំខាន់មួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានបង្កើតឡើងយ៉ាងល្អ ព្រមទាំងជាធាតុផ្សំសំខាន់នៃនីតិរដ្ឋ។

សិទ្ធិនេះ ជាចំណែកក្នុងការជៀសវាងការខុសឆ្គងនៃក្នុងការជម្រះក្តីដោយភាន់ច្រឡំរបស់តុលាការ ដើម្បីការពារជនជាប់ចោទពីការបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដោយមិនគិតពីពិរុទ្ធភាព ឬភាពគ្មានទោសតាមរយៈការប្រើប្រាស់កម្លាំងបង្ខិតបង្ខំ និងទារុណកម្ម។



# ដែនកំណត់

ការហាមឃាត់ការធ្វើទារុណកម្មដែលរួមបញ្ចូលក្នុងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺមានលក្ខណៈដាច់ខាត។ មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលហាមឃាត់ការធ្វើទារុណកម្ម និងទម្រង់ផ្សេងទៀតនៃការធ្វើបាបមិនត្រូវបានដកហូតគ្រប់ដំណាក់កាលទាំងអស់។ គ្មានកាលៈទេសៈ ឬហេតុផលណាមួយអាចអនុញ្ញាតឱ្យមានការប្រើប្រាស់ទារុណកម្ម ឬការធ្វើបាបផ្សេងទៀត ដើម្បីទទួលបានការសារភាពពីនរណាម្នាក់ឡើយ។





ហេតុដូចនេះ ចម្លើយដាក់បន្ទុកលើខ្លួនឯង ឬការសារភាពណាមួយដែលទទួលបានដោយមិនស្ម័គ្រចិត្តមិនមានតម្លៃជាភស្តុតាងឡើយ។ លើកលែងតែចម្លើយ ឬការសារភាពដែលទទួលបានដោយរំលោភបំពានលើមាត្រា៧ ប្រសិនបើចម្លើយទាំងនោះត្រូវបានប្រើប្រាស់ជាភស្តុតាងថាទារុណកម្ម ឬការប្រព្រឹត្តផ្សេងទៀតត្រូវបានហាមឃាត់តាមមាត្រានេះបានកើតឡើង។ ហេតុដូចនេះ ជនសង្ស័យ/ជនជាប់ចោទប្រើប្រាស់សិទ្ធិនេះដោយសេរីក្នុងការមិនផ្តល់ភស្តុតាង ដែលអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងពួកគេ។

សិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹងសិទ្ធិនៅស្ងៀម ដែលមានចរិកលក្ខណៈដាច់ខាត និងជាកម្មវត្ថុនៃការយល់ឃើញខុសៗគ្នា ដោយសារតែប្រទេសមួយចំនួនអនុញ្ញាតឱ្យមានការធ្វើសេចក្តីសន្និដ្ឋានជំទាស់ ពីភាពនៅស្ងៀមរបស់ជនជាប់ចោទនៅអំឡុងពេលសាកសួរជាបន្ទុកនៃពិរុទ្ធភាព។

លើសពីនេះសិទ្ធិមិនត្រូវការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់ជនជាប់ចោទគឺត្រូវបានរឹតត្បិតចំពោះសិទ្ធិនៅស្ងៀមដែលសិទ្ធិនេះបានធានាដល់ជនជាប់ចោទពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង ប៉ុន្តែមិនរារាំងព្រះរាជអាជ្ញាពីការបង្កើតភស្តុតាងជាសម្ភារៈនៅពេលជំនុំជម្រះ ដូចជាឯកសារ ឈាម ឬសំណាករាងកាយផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ជនជាប់ចោទ និងដែលអាចដាក់បន្ទុកលើពួកគេ។



ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA